**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៤ ៦៨៣នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទី១ស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) របស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) នេះ នឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៤០ ៥០០រៀល (១០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ៣០ថ្ងៃ
- ២០២ ៥០០រៀល (៥០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៣១ថ្ងៃ ដល់ ៤៩ថ្ងៃ
- ២៤៣ ០០០រៀល (៦០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៥០ថ្ងៃ ដល់ ២ខែ។

ក្រសួងសូមរំឮកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៩កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្ដីជូនដំណឹងចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ៤៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល លើកទី២ (បើកបញ្ចប់)

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 30 |
| 1 | ក្រុមហ៊ុនវូដុងអ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 2 | ក្រុមហ៊ុនអេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុនសានស៊ូ ខ្លូស៊ីង (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុនម៉ាកាឡូត ហ្គាមិន (ខេមបូឌា) សាខាទី ១ | ភ្នំពេញ |
| 5 | ក្រុមហ៊ុនស៊ីម៉ូនី អេស៊ីស៊ី ខឺលេកសិន | ភ្នំពេញ |
| 6 | ក្រុមហ៊ុនថុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុនហ្វអេវើ ហ្វូជ ព្រីនធីង | ភ្នំពេញ |
| 8 | ក្រុមហ៊ុនវី.ស៊ី.អូ.អេហ្វ.អេហ្វ អឹកែរីល ឯ.ក | ភ្នំពេញ |
| 9 | ក្រុមហ៊ុនគ្រាកស៍ អឹកែរីល (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 10 | រោងចក្រកាត់ដេរសម្លៀកបំពាក់ យូ.ឌី.អេស ហ្គាមេន | ភ្នំពេញ |
| 11 | ក្រុមហ៊ុន អ៊ិនធើ ហូបវែល ហ្គាមេន ខូអិលធីឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុនឌី&ជេ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុនហ៊ី លី តូ នីតធីង ខូ អិលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុនប្រូដឡែនខេមបូឌាហ្គាមែនអ៊ិនឌិសស្ទ្រី | ភ្នំពេញ |
| 15 | ក្រុមហ៊ុនភីភីអិន ភីសយ អឹថយខូអិលធីឌី | កណ្ដាល |
| 16 | ក្រុមហ៊ុនតេហ៊្សុអាំប្រេឡឺខូអិលធីឌី | កណ្ដាល |
| 17 | ក្រុមហ៊ុនដា រ៉ុង ព្រីនធីង & អ៊ឹមប្រយឌើរី | កណ្ដាល |
| 18 | ក្រុមហ៊ុនលៀនហ្វា (ខេមបូឌា) ហ្គាមេន | កណ្ដាល |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| 19 | ក្រុមហ៊ុនឃី ជា មេនូហ្វេកឆឺរី | កណ្តាល |
| 20 | ក្រុមហ៊ុនចុង យ៉ូវ | កណ្តាល |
| 21 | ក្រុមហ៊ុនញូខាំមើ ឡាក់ហ្គេជ អេនប៊ែក (ខេមបូឌា) មេនូហ្វេកធើរីង ឯ.ក | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុនអិមអេ ហ៊ែនប៊ែក (ខឹមបូឌា)ខូអេលធីឌី | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុនព្រេត ភីស លីមីធីត | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុនខេមបូឌានស៊ីកនេតឈ័រ ថេកស្តាយ ឯ ក | ស្វាយរៀង |
| 25 | ក្រុមហ៊ុនឃីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 26 | ក្រុមហ៊ុនអ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 27 | ក្រុមហ៊ុនកៅវ៉េ ស្ព័ត អិលធីឌី | ស្វាយរៀង |
| 28 | ក្រុមហ៊ុនឡាយហ្វេងអៅជរ(ខេមបូឌា)ឯ.ក | តាកែវ |
| 29 | ក្រុមហ៊ុនណាតផាក (ខេមបូឌា) ឯ.ក | ព្រះសីហនុ |
| 30 | ក្រុមហ៊ុនធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |
| ខ. វិស័យទេសចរណ៍ | | 14 |
| 31 | ក្រុមហ៊ុនអេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 32 | ក្រុមហ៊ុនសហគ្រាស-គ្រឹះស្ថាន ផ្លេនថេសិន ហូថេល | ភ្នំពេញ |
| 33 | ផ្ទះសំណាក់ប្លូមហ្គាឌិន | សៀមរាប |
| 34 | ក្រុមហ៊ុនណាវូទូ ឌ្រីម | សៀមរាប |
| 35 | ក្រុមហ៊ុនរេសចឺរេន ខូឡិចហ្សិន | សៀមរាប |
| 36 | ក្រុមហ៊ុនទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 37 | ក្រុមហ៊ុនអាហ្សូណា កាហ្វេធើរ៉ា | សៀមរាប |
| 38 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 39 | ក្រុមហ៊ុនអេច ឌី វ៉ក កាហ្វេ & សប | សៀមរាប |
| 40 | ក្រុមហ៊ុនចាយ៉ាហៅស៍រីវើរផាក សៀមរាប ឯ.ក | សៀមរាប |
| 41 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 42 | ក្រុមហ៊ុនភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 43 | ក្រុមហ៊ុនឋានសួគ៌សុខា | កំពត |
| 44 | ក្រុមហ៊ុនថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |